ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

សេចក្តីប្រកាសព័ត៌មាន
ស្តីពី
ការតែងតាំង និង ប្រគល់ភារកិច្ច
ជូនប្រធានក្រុមប្រឹក្សាភិបាលថ្មី និងអគ្គនាយកស្តីទី នៃទូរគមនាគមន៍កម្ពុជា

នៅព្រឹក ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៦ នាសាលប្រជុំទូរគមនាគមន៍កម្ពុជា មានប្រារព្ធពិធីប្រកាសតែងតាំង និងប្រគល់ភារកិច្ចជូនប្រធានក្រុមប្រឹក្សាភិបាលថ្មី និងអគ្គនាយកស្តីទី នៃទូរគមនាគមន៍កម្ពុជា ក្រោមអធិបតីភាពរបស់ **ឯកឧត្តម ប្រាក់ សុខុន** **រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍** និងដោយមានការអញ្ជើញចូលរួមពីសំណាក់ថ្នាក់ដឹកនាំក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ថ្នាក់ដឹកនាំទូរគមនាគមន៍កម្ពុជា និងតំណាងនៃបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធ។

ការផ្លាស់ប្តូរថ្នាក់ដឹកនាំសហគ្រាសសាធារណៈនេះ មានដូចតទៅ៖

- ឯកឧត្តម **ខូ រ មករា** អនុរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ត្រូវបានតែងតាំងជាប្រធានក្រុមប្រឹក្សាភិបាលទូរគមនាគមន៍កម្ពុជា ជំនួសឯកឧត្តម **មាស ប៉ូ** ដែលត្រូវបានបញ្ចប់មុខតំណែងជាប្រធានក្រុមប្រឹក្សាភិបាល។
- លោក **សន រ៉ី** អគ្គនាយករងនៃទូរគមនាគមន៍កម្ពុជា ត្រូវបានប្រគល់ភារកិច្ចជាអគ្គនាយកស្តីទី នៃទូរគមនាគមន៍កម្ពុជា ជំនួសឯកឧត្តម **ឡាយ ម៉ារ៉ី** ដែលត្រូវបញ្ចប់មុខតំណែងពីប្រតិកូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃទូរគមនាគមន៍កម្ពុជា។
- នៅក្នុងដំណើរការនៃការកែសំរួលរចនាសម្ព័ន្ធដឹកនាំរបស់អង្គភាពនេះ សមាសភាពក្រុមប្រឹក្សាភិបាលត្រូវបានកាត់បន្ថយមកត្រឹម ៥ រូប គឺ៖
  - តំណាងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ១ រូប ជាប្រធាន
  - តំណាងទីស្តីការគណៈរដ្ឋមន្ត្រី ១ រូប ជាសមាជិក
  - តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ១ រូប ជាសមាជិក
  - អគ្គនាយកទូរគមនាគមន៍កម្ពុជា ១ រូប ជាសមាជិក
  - តំណាងនិយោជិតរបស់ទូរគមនាគមន៍កម្ពុជា ១ រូប ជាសមាជិក
- ជាមួយនេះដែរ អគ្គនាយករងមួយរូបនឹងត្រូវបានជ្រើសរើសយកមកពីវិស័យឯកជន ដើម្បីជួយស្តារ និងពង្រឹងបន្ថែមស្ថានភាពអាជីវកម្ម និងបង្កើនចំណូលរបស់អង្គភាព។

ការផ្លាស់ប្តូរកែសំរួលរចនាសម្ព័ន្ធដឹកនាំនៃទូរគមនាគមន៍កម្ពុជា ត្រូវបានធ្វើឡើងបន្ទាប់ពីលទ្ធផលនៃអធិការកិច្ចរួមមួយរវាងអគ្គាធិការដ្ឋាននៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងក្រុមការងារនៃអង្គភាពប្រឆាំងអំពើពុករលួយ បានរកឃើញថា មានការខ្វះខាតធ្ងន់ធ្ងរ លើការងារគ្រប់គ្រង និងការដឹកនាំរបស់ថ្នាក់ដឹកនាំទូរគមនាគមន៍កម្ពុជាដែលនាំឲ្យ៖

- មានការកិបកេងលួចបន្លំយកប្រាក់ចំណូលរបស់អង្គភាពចំនួន ២៣ ម៉ឺនដុល្លារអាមេរិកប្រាកដមែន
- ការគ្រប់គ្រងចំណូល-ចំណាយមិនច្បាស់លាស់ គ្មានប្រសិទ្ធភាព តម្លាភាពនិងគណនេយ្យភាព ធ្វើឲ្យចំណូលធ្លាក់ចុះ បំណុលកើនឡើងជាលំដាប់ និងមានចន្លោះប្រហោងជាច្រើនដែលឈានទៅដល់ការកិបកេង និងការលុបបំណុល
- មិនបានយកចិត្តទុកដាក់ត្រួតពិនិត្យការគ្រប់គ្រងកិច្ចបញ្ជីការគណនេយ្យ និងឯកសារពាក់ព័ន្ធដែលឈានទៅដល់ការបាត់បង់ឯកសារដ៏មានសារៈសំខាន់ទាំងនេះដោយចេតនា។

នេះគឺជាការអនុវត្តតាមអភិក្រម **«ឆ្នុះកញ្ចាក់ ងូតទឹក ដុសក្បែល និងព្យាបាល»** ដែលសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី បានណែនាំដល់មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់តាំងពីដើមអាណត្តិទី ៥ នេះ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែកុម្ភៈ ឆ្នាំ២០១៦